ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
លេខ......១០៤......ន-សផក

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០២៣

សូមគោរពជូន

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ:** អំពីរបាយការណ៍កែលម្អតាមអនុសាសន៍សវនកម្មផ្ទៃក្នុង បានផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទ២០២១ នៅអគ្គនាយកដ្ឋានសំណង់

**យោង:**
- លិខិតលេខ១២៣ ជនស/អរប/សផក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ស្តីពីការអនុវត្តផែនការសវនកម្ម និងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ០៩៤ នា.សផក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ស្តីពីចុះតាមដានអនុសាសន៍នៅអគ្គនាយកដ្ឋានសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពអនុញ្ញាតជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ប្រតិភូសវនកម្មបានចុះពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មផ្ទៃក្នុង នៅអគ្គនាយកដ្ឋានសំណង់ ដែលប្រតិភូសវនករផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធបានផ្តល់អនុសាសន៍ ដូចខាងក្រោម÷

១. អគ្គនាយកដ្ឋានសំណង់ ត្រូវជំរុញនាយកដ្ឋានពាក់ព័ន្ធ ឱ្យអនុវត្តការងារក្នុងសៀវភៅចុះលេខចេញចូល ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និងត្រូវចុះហត្ថលេខាបិទនាពេលចុងឆ្នាំ។

២. អគ្គនាយកដ្ឋានសំណង់ ត្រូវជំរុញនាយកដ្ឋានសិក្សាគម្រោងប្លង់ ឱ្យភ្ជាប់ឯកសារសម្រាប់ទូទាត់ថវិកាទូទាត់គ្រប់ចំនួន២២.០០២.០០០រៀល ក្នុងនោះថវិកាចំនួន៧.៨០០.០០០រៀល សម្រាប់ដឹកជញ្ជូនសម្ភារៈ ឱ្យបានគ្រប់ចំនួន។

៣. អគ្គនាយកដ្ឋានសំណង់ ត្រូវជំរុញនាយកដ្ឋានសំណង់ឱ្យថតចម្លងទិដ្ឋាការធ្វើដំណើរ និងរបាយការណ៍លទ្ធផលការងារចុះបេសកកម្មឱ្យបានគ្រប់ចំនួន។

ឆ្លងតាមការពិនិត្យតាមអនុសាសន៍បានផ្តល់ឱ្យខាងលើ និងការបំភ្លឺបង្ហាញថា អង្គភាពរងសវនកម្មបានយកចិត្តទុកដាក់ក្នុងការកែលម្អនិងបានលទ្ធផលដូចខាងក្រោម÷

១. តាមការពិនិត្យសៀវភៅចុះលិខិតចេញ ចូល របស់នាយកដ្ឋានទាំងបី នៃអគ្គនាយកដ្ឋានសំណង់ ឆ្នាំ២០២២ អនុវត្តបានពេញលេញ ត្រឹមត្រូវ និងបានចុះហត្ថលេខាបិទនាពេលចុងឆ្នាំពីប្រធានអង្គភាពហើយ។

២. នាយកដ្ឋានសិក្សាគម្រោងប្លង់ បានថតចម្លងឯកសារសម្រាប់ទូទាត់ថវិកាខាងលើពីនាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញកិច្ចរបស់ក្រសួង បានគ្រប់ចំនួនហើយ។

៣. នាយកដ្ឋានសំណង់ បានថតចម្លងទិដ្ឋាការធ្វើដំណើរ និងរបាយការណ៍លទ្ធផលការងារចុះបេសកកម្ម បានគ្រប់ហើយ។

ទន្ទឹមនឹងនោះក៏នៅមានចំណុចសេសសល់ និងខ្វះខាតបន្តិចបន្តួចដែលនាយកដ្ឋានទាំងបីនៃអគ្គនាយកដ្ឋានសំណង់ នឹងធ្វើការកែលម្អបន្ថែមទៀត ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ ។

**បានឃើញ និងគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាប និងមានមតិដឹកនាំ**

ថ្ងៃពុធ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ប្រធាននាយកដ្ឋាន**

**យួន_សុជាតិ**

**ប្រធានប្រតិភូ**